ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីប្រកាសព័ត៌មាន

ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយអគ្គនាយកដ្ឋានពន្ធដារ

**ឯកឧត្តម គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានដឹកនាំគណៈប្រតិភូរបស់អគ្គនាយកដ្ឋានពន្ធដារទៅចូលរួមកិច្ចប្រជុំពេញអង្គលើកទី០៤របស់ក្រុមការងារ OECD និងការអភិវឌ្ឍន៍ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី ៣០ និង ៣១ ខែតុលា ឆ្នាំ២០១៣ នៅសាធារណៈរដ្ឋកូរ៉េ ។ ក្នុងកិច្ចប្រជុំនោះមានការចូលរួមពីបណ្ដាប្រទេសជាង៤០ប្រទេសដូចប្រទេសមកពីសហគមន៍អ៊ឺរ៉ុប អាហ្វ្រិក អាស៊ី និងអាមេរិចខាងជើងនិងខាងត្បូង ហើយការមានការចូលរួមពីស្ថាប័នអន្តរជាតិមួយចំនួនទៀតផងដែរដូច ធនាគារពិភពលោក សហគមន៍អ៊ឺរ៉ុប អង្គការសហប្រជាជាតិ ។ល។ កិច្ចប្រជុំនេះបានផ្ដោតទៅលើចំណុចសំខាន់ៗ ដូចខាងក្រោម៖




**ឯកឧត្តម គង់ វិបុល** អញ្ជើញផ្ដល់កិត្តិយស ថតរូបជាអនុស្សាវរីយ៍ជាមួយឯកឧត្តម អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៃសាធារណៈរដ្ឋកូរ៉េ និងថ្នាក់ដឹកនាំពីបណ្ដាប្រទេសនានា និងអង្គការសំខាន់ៗក្នុងកិច្ចប្រជុំពេញអង្គលើកទី០៤របស់ក្រុមការងារ OECD និងការអភិវឌ្ឍន៍

១- ការកាត់បន្ថយនូវមូលដ្ឋានគិតពន្ធ (Tax Base Erosion)

២- ការបង្វែរប្រាក់ចំណេញចេញក្រៅប្រទេស (Transfer Pricing)

៣- តម្លាភាព ការដោះដូរព័ត៌មាន និងការដោះស្រាយស្ដីពីការគេចវេះពន្ធ និងលំហូរនៃហិរញ្ញវត្ថុខុសច្បាប់ (Transparency, Exchange of Information and Illicit Financial Flow)



**ឯកឧត្តម គង់ វិបុល** អញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គលើកទី០៤របស់ក្រុមការងារ OECD និងការអភិវឌ្ឍន៍

៤- គោលនយោបាយសារពើពន្ធ សារពើពន្ធសម្រាប់ធនធានក្នុងស្រុក ការលើកទឹកចិត្តទាំងឡាយដែលទាក់ទងនឹងពន្ធដារ និងការបង្កើតនូវគោលនយោបាយដោយផ្អែកលើភស្តុតាង (Tax Policy: Natural Resource Taxation, Tax Incentives and Evidence-Based Policy Design)

៥- ជំនួយ កិច្ចសហប្រតិបត្តិសម្រាប់ការអភិវឌ្ឍន៍ និងសារពើពន្ធ (Aid, Development Cooperation and Taxation)

នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣ **ឯកឧត្តម គង់ វិបុល** ក៏បានចូលរួមកិច្ចប្រជុំពិសេសស្ដីពីការបង្កើតនូវបណ្ដាញពន្ធដារសម្រាប់អាស៊ីអាគ្នេយ៍ ដែលរៀបចំឡើងដោយកិច្ចសហការគ្នារវាង OECD ធនាគារពិភពលោក និងក្រសួងហិរញ្ញវត្ថុនៃសាធារណៈរដ្ឋកូរ៉េ។ ក្នុងកិច្ចប្រជុំនោះគឺផ្ដោតសំខាន់ទៅលើពង្រឹងបណ្ដាញសារពើពន្ធឲ្យបានតែរឹងមាំនៅអាស៊ីអាគ្នេយ៍និងនៅអាស៊ីទាំងមូលផងជាពិសេសគឺចង់ស្វែងរកនូវលទ្ធភាពក្នុងការបង្កើតនូវក្រុមការងារសារពើពន្ធនៅក្នុងតំបន់។